នស/រកត/១០០៥/៤៤៤

# ព្រះរាជក្រឹត្យ

## ស្តីពី

## ការកែសំរួលមាត្រា៨ មាត្រា១០ នៃព្រះរាជក្រឹត្យ

## លេខ នស/រកត/០៥០១/១៧៨ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១

## ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០០៤ ដែលប្រកាស អោយប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/ ០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :-**

ត្រូវបានកែសំរួលមាត្រា៨ និងមាត្រា១០ ជំពូកទី២ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិដូចខាងក្រោម :

**មាត្រា៩ថ្មី :-**

ការប្រលងជ្រើសរើសអោយចូលជានាយនគរបាលរង ត្រូវធ្វើចំពោះបេក្ខជនជាសិស្សទាំងពីរភេទដែលមានសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិឬសញ្ញាប័ត្រដែលមានតម្លៃស្មើ និងសញ្ញាប័ត្រក្រោមមធ្យមសិក្សាទុតិយភូមិ ហើយមានអាយុយ៉ាងច្រើនបំផុត ២៥ឆ្នាំ គិតរហូតដល់ថ្ងៃប្រលង ។ បើជាមន្ត្រីរាជការក្នុងក្របខ័ណ្ឌ បេក្ខជនត្រូវមានសញ្ញាប័ត្រយ៉ាងទាបបំផុតមធ្យមសិក្សាទុតិយភូមិ ឬ សញ្ញាប័ត្រដែលមានតម្លៃស្មើ និងមានអាយុយ៉ាងច្រើនបំផុត ៣០ឆ្នាំ គិតរហូតដល់ថ្ងៃប្រលង ។

**មាត្រា១០ថ្មី :-**

ក្រោយការបណ្តុះបណ្តាលសិស្សនាយនគរបាល និងសិស្សនាយនគរបាលរង ត្រូវបានតាំងស៊ប់ក្នុងក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា ។

សិស្សនាយនគរបាលត្រូវបានតែងតាំងឋានន្តរសក្តិថ្នាក់នាយចំណង់ ។

សិស្សនាយនគរបាលរងត្រូវបានតែងតាំងឋានន្តរសក្តិថ្នាក់ព្រិន្ទបាលទោ ចំពោះអ្នកមានសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ និងឋានន្តរសក្តិថ្នាក់ពលបាលត្រី ចំពោះអ្នកមានសញ្ញាប័ត្រក្រោមមធ្យមសិក្សាទុតិយភូមិ។

**មាត្រា២ :-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា៣ :-**

សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះឱ្យបានសំរេច ។

**មាត្រា៤ :-**

ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៦ស-០៥១០.៤៧៣

ធ្វើនៅព្រះបរមរាជវាំង, រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០០៥

លេខ ៤១៦ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ ១៧ ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល
ណាឌី តាន់